## ១៦ សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «គ្រប់គ្រងសណ្ដាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍»

### ក- រូបសញ្ញា




### ខ- សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «គ្រប់គ្រងសណ្ដាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍»

មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរូបរាងជាខែលការពារ ពទ្ធទ្រពីខាងក្រោមដោយក្បាច់ភ្ញីទេសពណ៌មាស។ សញ្ញានេះមានទំហំកម្ពស់២,៩ស.ម. និងទទឹង១,៧ស.ម.
- ផ្នែកខាងលើ មានមកុដរាជតម្កល់នៅពីលើខែលការពារ ហើយកំពូលមកុដរាជមានពន្លឺរស្មីដែលរះចែងចាំងពណ៌មាសចំនួន២៥ តំណាងឱ្យរាជធានី ខេត្តទាំង២៥ក្នុងព្រះរាជាណាចក្រកម្ពុជា។
- ផ្នែកកណ្ដាលខាងលើនៃខែលការពារមានរូបព្រះគណេសពាក់កណ្ដាលខ្លួនពណ៌មាស មានផ្ទៃខាងក្រោយពណ៌ប្រាក់។
- នៅខាងក្រោមព្រះគណេស មានផ្កាចន្ទន៍ចំនួន៧ ដែលតំណាងឱ្យសាលានគរបាលជាតិចំនួន៧ នៅតាមបណ្ដាខេត្តនៃព្រះរាជាណាចក្រកម្ពុជា។
- នៅខាងក្រោមផ្កាចន្ទន៍ទាំង៧ មានភ្លើងសញ្ញាចរាចរណ៍ទាំងបីពណ៌ ដែលមានស៊ុមពណ៌ផ្លាទីន។

- រីឯផ្នែកខាងក្រោម រំលេចដោយបូមានពណ៌ក្រហមនិងខៀវ ហើយក្នុងផ្ទៃបូមានសរសេរឈ្មោះវគ្គ «**គ្រប់គ្រង.ចរាចរណ៍**» ពណ៌មាស។

**ខ.២- អត្ថន័យ**

- **សន្ទឹកក្បាច់ភ្ញីទេស** តំណាងឱ្យការរីកចម្រើនលូតលាស់រុងរឿង សម្បូរសប្បាយ
- **ពន្លឺឆព្វណ្ណរង្សី** ស្ថិតនៅពីលើគេ តំណាងឱ្យគំនិត ប្រាជ្ញា ស្មារតី
- **មកុដរាជ** តំណាងឱ្យអំណាចរបស់ព្រះមហាក្សត្រ ដែលផ្តល់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រ និងសិទ្ធិអំណាចដល់ស្ថាប័នជាតិ ក្នុងការថែរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- **ខែល** តំណាងឱ្យគ្រឿងបិទបាំងការពារគ្រប់មុំទាំងខាងមុខនិងខាងក្រោយ ដែលបង្ហាញលក្ខណៈរឹងមាំនៃកងកម្លាំងនគរបាលជាតិក្នុងការប្រយុទ្ធប្រឆាំង ទប់ស្កាត់រាល់បទល្មើស
- **ព្រះគណេស** ជាអាទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គ និងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះ ព្រះគណេសតំណាងឱ្យភាពជាអ្នកប្រាជ្ញ ជាបណ្ឌិត ជាអ្នកចេះដឹង អ្នកជួយដល់សត្វទាំងឡាយគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ព្រមទាំងបង្កើតឱ្យមានភាពសម្បូររុងរឿង វឌ្ឍនភាព និងវិបុលភាព
- **បូមានពណ៌ក្រហមនិងខៀវ** រំលេចវគ្គសិក្សា «**គ្រប់គ្រង.ចរាចរណ៍**» ពណ៌មាសនៅចំកណ្តាល តំណាងឱ្យសន្តិសុខ សុវត្ថិភាពសង្គម សុខសន្តិភាព សាមគ្គីភាព ភាតរភាព និងនិរន្តរភាព ព្រមទាំងបង្ហាញពីភាពមោះមុត អង់អាចក្លាហាន និងការប្តេជ្ញាចិត្ត ក្នុងនាមកងកម្លាំងនគរបាលសណ្តាប់ធ្នាប់ចរាចរណ៍ ក្នុងការសម្រួលចរាចរណ៍ជូនប្រជាពលរដ្ឋគ្រប់រូប។
- **ពណ៌មាស** តំណាងឱ្យពន្លឺនៃវិជ្ជាអប់រំបញ្ញា ប្រាជ្ញាស្មារតី ភាពឧត្តុង្គឧត្តម សេចក្តីថ្លៃថ្នូរ គុណតម្លៃកងកម្លាំង និងប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា
- ពាក្យ «**គ្រប់គ្រង.ចរាចរណ៍**» ជាឈ្មោះនៃវគ្គបណ្តុះបណ្តាល ដែលបណ្ឌិត្យសភាធ្វើការបណ្តុះបណ្តាលដល់សិក្ខាកាមដែលជាមន្ត្រីនគរបាលសណ្តាប់ធ្នាប់ចរាចរណ៍នៃក្រសួងមហាផ្ទៃ។
- រូបរាងសញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «**គ្រប់គ្រងសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍**» ដូចមានភ្ជាប់ក្នុងសេចក្តីពន្យល់នេះ។
- សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «**គ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍**» ត្រូវបានប្រើប្រាស់ដោយបំពាក់ជាប់គម្របហោប៉ៅអាវឬបំពាក់ពីលើហោប៉ៅអាវផ្នែកខាងស្តាំ។